ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៤ លេខ ១ | មករា - មីនា ឆ្នាំ២០១០ | តម្លៃ ១.៥០០៛

20
ខួបលើកទី
CDRI 1990-2010

# ការរឹតត្បិតឥណទាន និងសាច់ប្រាក់: ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រព័ន្ធធនាគារនៅកម្ពុជា[១]


ធនាគារជាតិនៃកម្ពុជា ជានិយតករដ៏សំខាន់សម្រាប់វិស័យធនាគារនៅកម្ពុជា

## សេចក្តីផ្តើម

ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលមកលើប្រទេសកម្ពុជា អាចមើលឃើញច្បាស់ណាស់ ។ គេគន់គូរថា កម្ពុជាស្ថិតក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីខាងកើត ដែលត្រូវរួមចុះកំណើនសេដ្ឋកិច្ចធ្ងន់ធ្ងរជាងគេ នៅឆ្នាំ២០០៩ (CDRI 2009c; World Bank 2009a, 2009b; ADB 2009; IMF 2009b, 2009c) ។ ឥទ្ធិពលវិបត្តិនេះ អាចពិនិត្យឃើញជាសំខាន់តាមការប៉ះទង្គិចទៅលើពាណិជ្ជកម្ម លំហូរមូលធន និងជាពិសេស ក្បាលម៉ាស៊ីនកំណើនរបស់កម្ពុជាតែម្តង ។ ទោះបីប្រព័ន្ធធនាគារក្នុងស្រុករបស់កម្ពុជាបានរួចផុតពីឥទ្ធិពលប៉ះទង្គិចនៅជុំទី១ ដោយសារមិនសូវមានជាប់ពាក់ព័ន្ធនឹងផលិតផលកម្ចីលេខពីរដែលគ្រោះថ្នាក់ខ្លាំងក្តី ប៉ុន្តែត្រូវប្រឈមមុខនឹងឧបសគ្គយ៉ាងច្រើន ដោយសារស្ថានភាពសេដ្ឋកិច្ចមិនល្អ និងការរឹងស្ងួតឥណទាន និងសាច់ប្រាក់ជាសាកល ។ ដូចស្ថានភាពសេដ្ឋកិច្ចសាកលលោកដែរ សេដ្ឋកិច្ចកម្ពុជា បានឆ្លងផុតចំណុចចុះទាបបំផុតរួចហើយ ប៉ុន្តែនៅមានហានិភ័យធំៗជាច្រើនទៀត (សូមមើល Jalilian *et al.* 2009; CDRI 2009a, 2009b, 2009c) ។ អត្ថបទនេះពិនិត្យពីផលប៉ះពាល់នៃវិបត្តិមកលើវិស័យធនាគារនៅកម្ពុជា ។

## ផលប៉ះពាល់លើប្រព័ន្ធធនាគារក្នុងស្រុក

ការរឹតត្បិតឥណទាន និងសាច់ប្រាក់ងាយស្រួលក្នុងស្រុក បង្ហាញច្បាស់ពីភាពតានតឹងនៃស្ថានភាពរូបិយវត្ថុទូទៅ ចាប់ពីពាក់កណ្តាលឆ្នាំ២០០៨ មក ទោះបីក្នុងប៉ុន្មានខែកន្លងទៅនេះ សកម្មភាពសេដ្ឋកិច្ច ឃើញថា បានប្រសើរឡើងវិញខ្លះៗក្តី ។ កំណើនរូបិយវត្ថុទូទៅពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះ

១ អត្ថបទនេះ រៀបចំដោយ Hossein Jalilian (នាយកផ្នែកស្រាវជ្រាវនៃ CDRI) និង Glenda Reyes (អ្នកស្រាវជ្រាវនៃ CDRI) ដោយសង្ខេបចេញពីរបាយការណ៍ព្រាងដែលរៀបចំសម្រាប់ជាឯកសារពិភាក្សាវិស័យហិរញ្ញវត្ថុសាកលនៃ Overseas Development Institute ។ របាយការណ៍នេះ នឹងត្រូវបញ្ចប់នាពេលឆាប់ៗខាងមុខ ។ការពិគ្រោះយោបល់ជាមួយអ្នកតំណាងផ្សេងៗក្នុងវិស័យធនាគារ ត្រូវបានធ្វើឡើង ដើម្បីជួយទ្រទ្រង់ និងបញ្ជាក់បន្ថែមលើការវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិទៅលើប្រព័ន្ធធនាគារ ។
អ្នកនិពន្ធ សូមអរគុណផងដែរដល់លោក សាំង ច័ន្ទហង្ស (អ្នកស្រាវជ្រាវនៃ CDRI) ដែលបានចូលរួមធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផ្សេងៗ ។

## មាតិកា

ការរឹតត្បិតឥណទាន និងសាច់ប្រាក់:ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រព័ន្ធធនាគារនៅកម្ពុជា ............១
ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកល លើភាពក្រីក្រ និងការអភិវឌ្ឍសង្គមនៅកម្ពុជា ................................ ៧
ការវិភាគពីរដ្ឋកម្ពុជាក្នុងលក្ខណៈ ជារដ្ឋជំរុញអភិវឌ្ឍន៍ ........១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស.......................១៥
— ស្ថានភាពក្នុងប្រទេស ...................... ១៧
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI .................................. ២៤

ក្រាហ្វិក ១: កំណើនរូបិយវត្ថុទូទៅ (បំលាស់ប្ដូរពីមួយឆ្នាំទៅមួយឆ្នាំ)




*ប្រភព: ធនាគារជាតិនៃកម្ពុជា (NBC)*

ចាប់ពីប្រហែល ៦០% នៅខែកុម្ភៈ ២០០៨ មកត្រឹម -១% ក្នុងឆ្នាំបន្ទាប់ រួចទើបកើនឡើងបន្តិចវិញ ដល់ប្រហែល ១៣% នៅខែសីហា ២០០៩ (ក្រាហ្វិក ១) ។

កាលពីមុន សូចនាករភាពរឹងមាំខាងហិរញ្ញវត្ថុ បង្ហាញថា ធនាគារក្នុងស្រុកគិតជារួម រក្សាបានស្ថានភាពរឹងប៉ឹង នៅពេលវិកផធំធាត់ ដោយមានមូលធនបង្ការ និងសាច់ប្រាក់ងាយស្រួលគ្រប់គ្រាន់ និងមានបញ្ហាតិចតួចខាងប្រាក់កម្ចី (Jalilian *et al.* 2009; IMF 2009a) ។ ចំនួនធនាគារ កើនឡើងយ៉ាងលឿន រហូតដល់ ធនាគារពាណិជ្ជ មាន ២៧ ធនាគាររដ្ឋ មាន ១ និងធនាគារឯកទេស មាន ៥ នាពេលបច្ចុប្បន្ន ។ មានស្ថាប័នធនាគារមួយចំនួនតូចប៉ុណ្ណោះ ដែលដើរតួសំខាន់ក្នុង ផសស ។ ទោះយ៉ាងនេះក្ដី ទ្រព្យសកម្មរបស់ធនាគារសរុប គិតជាចំណែកនៃ ផសស បានកើនឡើងពី ២៦% នៅខែធ្នូ ២០០៦ មកដល់ ៤៧% នៅខែធ្នូ ២០០៨ ហើយប្រាក់កម្ចីគិតជាភាគរយនៃ ផសស កើនឡើងប្រហែល ១១% (ធនាគារជាតិនៃកម្ពុជា) ។

បន្ទាប់ពីនោះមក គេឃើញមានការតានតឹងកាន់តែខ្លាំងឡើង ដោយធនាគារត្រូវប្រឈមមុខនឹងហានិភ័យកាន់តែធំខាងឥណទាន និងសាច់ប្រាក់ងាយស្រួល ។ ប្រហែល ៩៧% នៃប្រាក់បញ្ញើនៅធនាគារសរុប ជាប្រាក់បញ្ញើជារូបិយប័ណ្ណ ហើយកាលពីខែកុម្ភៈ ២០០៨ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃប្រាក់បញ្ញើប្រភេទនេះ មានប្រហែល ៧០% ប៉ុន្ដែមួយឆ្នាំក្រោយមក វាបានធ្លាក់ចុះមកត្រឹម -៤% (ក្រាហ្វិក ១) ។ គេរាយការណ៍ថា មានការដកប្រាក់ច្រើនៗមួយចំនួនជារូបិយប័ណ្ណ ហើយក៏មានការដាក់បញ្ចូលមូលនិធិបន្ទាន់ពីក្រុមហ៊ុនមេនៅឯបរទេស ដែលធ្វើឱ្យប្រព័ន្ធធនាគារត្រូវពឹងផ្អែកខ្លាំងទៅលើមូលធនពីបរទេស[២] ។

នៅដើមឆមាសទី២ ឆ្នាំ២០០៩ សាច់ប្រាក់ងាយស្រួល បានកើនឡើងបន្ដិចវិញ នាំឱ្យមានការវាយតម្លៃថា គ្រោះថ្នាក់លើសាច់ប្រាក់ងាយស្រួលបានកន្លងផុតហើយ ។ នៅខែសីហា កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណពីមួយឆ្នាំទៅមួយឆ្នាំ មាន ១១% ។ អនុបាតសាច់ប្រាក់ងាយស្រួល បានកើនឡើង (ខ្ពស់ល្អជាងកម្រិតប្រុងប្រយ័ត្ន) ពី ៨១% នៅចុងឆ្នាំ២០០៨ ដល់ ៩៣% នៅខែសីហា ២០០៩ (ក្រាហ្វិក ២) ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានយល់ស្របថា បច្ចុប្បន្ននេះ សាច់ប្រាក់ងាយស្រួល មានគ្រប់គ្រាន់នៅក្នុងប្រព័ន្ធធនាគារ (IMF 2009b) ហើយអ្នកតំណាងរបស់វិស័យធនាគារក្នុងស្រុកក៏ឯកភាពដូច្នេះដែរ ប៉ុន្ដែគេបានលើកពីការបារម្ភខ្លះលើបញ្ហាសាច់ប្រាក់ងាយស្រួលដែលប្រមូលផ្ដុំនៅក្នុងធនាគារធំៗ និងហានិភ័យនៃការធ្លាក់ចុះវិញ ដែលអាចធ្វើឱ្យស្ថានភាពប្រែប្រួលក្រឡាប់ចាក់ (ការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ) ។

ផ្ទុយទៅវិញ ការព្រួយបារម្ភលើហានិភ័យនៃឥណទាន ដែលពិនិត្យឃើញតាមរយៈការប្រុងប្រយ័ត្នជាបន្តទៀតក្នុងការផ្ដល់កម្ចីទៅដល់វិស័យឯកជននោះ គឺមិនទាន់រលាយបាត់អស់នៅឡើយទេ បើទោះជាអារម្មណ៍ភ័យព្រួយនេះប្រែប្រួលទៅតាមកម្រិតធ្ងន់ធ្ងរនៃហានិភ័យក៏ដោយ ។ កំណើនឥណទានវិស័យឯកជនពីមួយឆ្នាំទៅមួយឆ្នាំ ធំលើស ១០០% នៅតាមខែនីមួយៗក្នុងត្រីមាសទី២ ឆ្នាំ២០០៨ ហើយនៅតែរក្សាកំណើនខ្លាំងដដែល គឺ ៥០% នៅចុងឆ្នាំ២០០៨ ។

ការរីកដុះដាលលឿននេះ ហាក់ដូចកើតឡើងជាមួយនឹងបញ្ហាខ្លះៗ ដែលធនាគារជាតិនៃកម្ពុជាបានព្យាយាមដោះស្រាយក្នុងកិច្ចប្រឹងប្រែងជួយការពារប្រព័ន្ធធនាគារក្នុងស្រុក កុំឱ្យជួបភាពតានតឹងកាន់តែខ្លាំងថែមទៀត ។ ចំណែកនៃឥណទានមិនដំណើរការ (NPL) នៅក្នុងឥណទានសរុប បានកើនឡើងពីប្រហែល ៣,៧% នៅចុងខែធ្នូ ២០០៨ ដល់ ៥,៩% នៅខែសីហា ២០០៩ (ក្រាហ្វិក ២) ។ ប៉ុន្ដែ វានៅតែជាចំណែកមួយតូចដដែល ជាពិសេសបើធៀប

២ នៅចុងខែធ្នូ ២០០៨ មូលធនពីបរទេស រួមចំណែកប្រហែល ៦៧% នៃមូលធនបានបង់ជំរះសរុបរបស់ប្រព័ន្ធធនាគារពាណិជ្ជ (NBC) ។

ក្រាហ្វិក ២: អនុបាតប្រុងប្រយ័ត្ននៃធនាគារ*** (គិតជា %)




*ប្រភព: ធនាគារជាតិនៃកម្ពុជា (NBC)*

*** អនុបាតប្រុងប្រយ័ត្ននៃធនាគារ ជាសូចនាករស្តីពីសុខភាពហិរញ្ញវត្ថុរបស់ធនាគារ ។ អនុបាតសាធនភាព និងអនុបាតសាច់ប្រាក់ងាយស្រួល បង្ហាញពីលទ្ធភាពរបស់ធនាគារក្នុងការសងបំណុលរយៈពេលខ្លី និងរយៈពេលវែងរបស់ខ្លួន រីឯអនុបាតមូលធនគ្រប់គ្រាន់ (ទ្រព្យម្ចាស់ធៀបនឹងទ្រព្យសកម្មសរុប) បង្ហាញពីលទ្ធភាពរបស់ធនាគារក្នុងការទប់ទល់នឹងការខាតបង់ជាសក្តានុពលផ្សេងៗ ។ អនុបាតបំណុលធៀបនឹងទ្រព្យសកម្មសរុប បង្ហាញពីភាគរយនៃទ្រព្យសកម្មរបស់ធនាគារដែលទទួលហិរញ្ញប្បទានពីការខ្ចីបុលជាជាងបានពីទ្រព្យម្ចាស់ ហើយអនុបាតឥណទានមិនដំណើរការ (NPL) បង្ហាញពីភាគរយនៃកម្ចីធនាគារ ដែលមិនត្រូវបានទូទាត់សង ឬប្រហែលជាមិនអាចទូទាត់សងវិញ ។

នឹងកំណើនយ៉ាងលឿននៃឥណទានកាលពីមុន ។ ម្យ៉ាងវិញទៀត កំណើនឥណទាននេះ អាចបណ្តាលមួយផ្នែកមកពីការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឥណទានដែលធនាគារជាតិនៃកម្ពុជាបានអនុវត្ត ដោយយោងតាមបទបញ្ញត្តិកាន់តែតឹងរ៉ឹងជាងមុន ស្តីពីការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្ម និងការធ្វើសំវិធានធន (ការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ)[៣] ។

ចំណែកនៃឥណទានរបស់ធនាគារផ្តល់ទៅឱ្យវិស័យអចលនទ្រព្យ (ក្រាហ្វិក ៣) ដែលមានហានិភ័យកើនខ្ពស់ ដោយសារអចលនទ្រព្យក្នុងស្រុកបានដួលរលំ និងឥទ្ធិពលពីវិបត្តិ តាមពិតមានមិនច្រើនប៉ុន្មានឡើយ ប៉ុន្តែរឿងនេះ អាចមិនត្រឹមត្រូវទាំងស្រុងទេ ព្រោះមានកម្ចីរបស់បុគ្គលឯកជនមួយចំនួន ក៏ប្រហែលបានយកមកប្រើប្រាស់ក្នុងសកម្មភាពខាងអចលនទ្រព្យដែរ ។ ដោយសារទំនាក់ទំនងជិតស្និទ្ធរវាងការសាងសង់ និងការអភិវឌ្ឍអចលនទ្រព្យក្នុងប្រទេស ឥណទានធនាគារដែលផ្តល់ទៅឱ្យវិស័យសំណង់ក៏មានចំណែកទទួលរ៉ាប់រងហានិភ័យដែលពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យដែរ ។ ការធ្វើកាលវិភាគថ្មីលើកម្ចី អាចជួយលាក់បាំងបញ្ហាឥណទានមិនដំណើរការតទៅទៀត[៤] ។ អនុបាតឥណទានមិនដំណើរការ រំពឹងថា អាចកើនខ្ពស់បំផុតដល់ ១០% នៅចុងឆ្នាំនេះ (សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចេញថ្ងៃទី ២៧ សីហា ២០០៩) ។

នៅខែសីហា ២០០៩ កំណើនប្រចាំឆ្នាំនៃឥណទានចំពោះវិស័យឯកជនបានធ្លាក់ចុះមកត្រឹម ៤% ប៉ុណ្ណោះ ដោយសារការប្រុងប្រយ័ត្នជាបន្តក្នុងការផ្តល់ឥណទាន ។ ក្នុងពេលជាមួយគ្នា ឥណទានធនាគារផ្តល់ទៅឱ្យវិស័យអចលនទ្រព្យ បានថយចុះមកត្រឹម ៦,៤% ធៀបនឹង ៧,៦% កាលពីឆ្នាំមុន (ក្រាហ្វិក ៣) ។ ផ្អែកតាមសូចនាករប្រុងប្រយ័ត្នផ្សេងៗ (ដូចជា អនុបាតសាច់ប្រាក់ងាយស្រួលបានលើកឡើងនៅខាងលើ និងអនុបាតមូលធនគ្រប់គ្រាន់) លទ្ធផលសំរេចបានអាចធ្វើឱ្យប្រព័ន្ធធនាគារមានសាច់ប្រាក់បង្ការគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាខាងឥណទាន ក៏ដូចជា ហានិភ័យផ្សេងៗ ។

មិនមែនមានតែធនាគារពាណិជ្ជ និងធនាគារឯកទេស ប៉ុណ្ណោះទេ ដែលទទួលរងនូវឥទ្ធិពលជុំទី២ នៃវិបត្តិ បណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs)

៣ សូមពិនិត្យផងដែរនូវប្រកាសស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញ និងការធ្វើសំវិធានធនក្នុងស្ថាប័នហិរញ្ញវត្ថុ និងធនាគារ ចុះនៅដើមឆ្នាំ២០០៩ និងចុះក្នុងគេហទំព័រ http://www.nbc.org.kh/read-prakas.asp?id=63 ។ ដោយសារការរីកដុះដាលនៃវិស័យធនាគារក្នុងឆ្នាំ២០០៨ និងការដាក់អនុវត្តប្រកាសខាងលើដែលបានបង្កើនសំវិធានធនតាមការតំរូវ ផលចំណេញលើចំណូលដុល (return on earnings) បានធ្លាក់ចុះពី ១៣,១១% នៅចុងឆ្នាំ២០០៨ មកត្រឹម ៣,៦៩% រីឯចំណូលពីទ្រព្យសកម្ម (return on asset) ធ្លាក់ចុះពី ២,៨៨% មកត្រឹម ០,៨២% (ទិន្នន័យរបស់ NBC) ។

៤ ក្នុងពេលពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ មានការលើកឡើងថា យុទ្ធសាស្ត្រអាចមានការ "កែច្នៃ" តារាងតុល្យការមួយចំនួនឱ្យល្អមើល ។ ឥណទានមានចោទបញ្ហាខ្លាំងមួយចំនួន ប្រហែលបានរៀបចំតារាងពេលឡើងវិញ ឱ្យទៅជាបំណុលរយៈពេលយ៉ាងវែង ដែលមានការបង់រំលោះតិចជាងមុន ។ ការអនុវត្តបែបនេះប្រហែលគ្រាន់តែអាចពន្យាពេលបញ្ហារបស់សាមីធនាគារប៉ុណ្ណោះ ។

ក្រាហ្វិក ៣: ចំណែកផ្សេងៗនៃឥណទានធនាគារ (គិតជា % នៃឥណទានសរុប)




*ប្រភព: ធនាគារជាតិនៃកម្ពុជា (NBC)*

ក៏រងឥទ្ធិពលនេះដែរ ថ្វីបើពីមុននោះ ហាក់ដូចពុំឃើញមានការប៉ះពាល់អ្វីសោះ ។ ដោយសារ MFIs នៅជិតជាប់ជាមួយអតិថិជននៅតាមទីជនបទ និងបានពង្រីកកម្ចីទៅដល់សហគ្រាសធនតូច និងមធ្យម និងទៅដល់វិស័យកសិកម្ម MFIs កាន់តែមានប្រជាប្រិយភាពខ្លាំងក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ទោះបីជាវិស័យនេះនៅតូច បើធៀបនឹងប្រព័ន្ធធនាគារពាណិជ្ជកម្ម (Jalilian *et al.* 2009) ។ ត្រឹមខែសីហា ២០០៩ មាន ២០ MFIs ដែលមានអាជ្ញាប័ណ្ណ និងមានអង្គការមិនមែនរដ្ឋាភិបាលអ្នកផ្តល់មីក្រូឥណទាន ចំនួន ២៥ អង្គការដែលបានចុះបញ្ជីរួច និងជាង ៦០អង្គការទៀត ដែលមិនទាន់ចុះបញ្ជី (NBC) ។

ថ្វីបើមានជាប់ពាក់ព័ន្ធតិចជាមួយឥណទានមានហានិភ័យខ្ពស់ (ដូចជាឥណទានដល់វិស័យអចលនទ្រព្យ និងសំណង់ ជាដើម) ក៏ដោយ ក៏ស្ថាប័នមីក្រូហិរញ្ញវត្ថុ ជួបការតឹងតែងកាន់តែខ្លាំងដែរ នៅពេលវិបត្តិកាន់តែធ្ងន់ធ្ងរឡើង ។ វិស័យនេះ ពឹងផ្អែកខ្លាំងលើមូលធនពីបរទេស[៥] ដូច្នេះហើយក៏ទទួលរងឥទ្ធិពលពីការស្ទះសាច់ប្រាក់ងាយស្រួលជាសាកល និងកំណើនការខ្លាចរអាហានិភ័យ ។ គេរាយការណ៍ថា អ្នកផ្តល់ឥណទានពីបរទេសមកឱ្យ MFIs ក្នុងស្រុក បានធ្វើការរឹតត្បិតឥណទាន ដែលបណ្តាលឱ្យមានការលុបកិច្ចសន្យាក្នុងករណីមួយចំនួន និងការតំឡើងថ្លៃហិរញ្ញប្បទាន ហើយជាលទ្ធផល MFIs ត្រូវផ្ទេរបន្ទុកចំណាយមួយភាគ ឬទាំងអស់លើការតំឡើងអត្រាការប្រាក់ទៅលើអតិថិជន (Chhun 2009) ។

សូចនាករប្រុងប្រយ័ត្ន ហាក់បង្ហាញថា MFIs អាចជៀសផុតពីផលប៉ះពាល់ភាគច្រើននៃវិបត្តិបានប្រសើរជាងពួកធនាគារពាណិជ្ជ ។ អនុបាតឥណទានមិនដំណើរការរបស់ MFIs បានឡើងដល់ ២,៧% នៅខែសីហា ២០០៩ ធៀបនឹង ០,៤% នៅចុងឆ្នាំ២០០៨ ប៉ុន្តែវាជាអត្រាមួយទាបទេ បើយើងពិចារណាដល់ការរីកដុះដាលយ៉ាងរហ័សនៃមីក្រូឥណទាន ។ កំណើនអត្រានេះ អាចបណ្តាលមួយចំណែកដោយសារការធ្វើចំណាត់ថ្នាក់ឥណទានឡើងវិញដែលតំរូវឡើងដោយធនាគារជាតិនៃកម្ពុជា ។ អនុបាតមូលធនគ្រប់គ្រាន់ ក៏កើនឡើងដែរ ពី ២០,៤% នៅឆ្នាំ២០០៨ ដល់ ២៣,៥% នៅខែសីហា ២០០៩ (NBC និងការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ) ។

សរុបមក វិស័យធនាគារនៅកម្ពុជា រួមទាំង MFIs និងអ្នកផ្តល់សេវាហិរញ្ញវត្ថុផ្សេងៗផង ហាក់ដូចមិនសូវប៉ះពាល់ធ្ងន់ធ្ងរដោយសារវិបត្តិទេ ។ ប៉ុន្តែអាចមានការប៉ាន់ស្មានទាបពេកពីផលប៉ះពាល់នៃវិបត្តិទៅលើវិស័យធនាគារ ហើយបញ្ហាពាក់ព័ន្ធផ្សេងៗ ប្រហែលអាចកើតមានឡើងចំពោះធនាគារមួយចំនួននៅពេលក្រោយទៀត ។

## គោលនយោបាយឆ្លើយតប

ភាពអន់ថយនៃវិស័យហិរញ្ញវត្ថុកម្ពុជា អាចជាកត្តានាំឱ្យកម្ពុជាគេចផុតពីឥទ្ធិពលជុំទី១ នៃវិបត្តិ ។ ប៉ុន្តែភាពអន់ថយនេះ ក៏ជាឧបសគ្គរាំងដល់សមត្ថភាពរបស់រដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីឆ្លើយតបឱ្យបានស័ក្តិសិទ្ធិជាងនេះ ចំពោះឥទ្ធិពលជុំទី២ នៃវិបត្តិ ។ ធនាគារជាតិនៃកម្ពុជា បានឆ្លើយតបបានទាន់ពេលគួរឱ្យកោតសរសើរចំពោះសំពាធក្នុងវិស័យហិរញ្ញវត្ថុ ក៏ពិតមែន ប៉ុន្តែសមត្ថភាពរបស់ធនាគារកណ្តាលដើម្បីធ្វើការងារឱ្យបានច្រើនថែមទៀត ត្រូវជួបឧបសគ្គនៃដុល្លារូបនីយកម្មក្រៅផ្លូវការដ៏ខ្លាំងក្លានៃសេដ្ឋកិច្ច ។ សមត្ថភាពពិនិត្យតាមដាន មានដែនកំណត់របស់ NBC និងឧបសគ្គខាងផ្លូវច្បាប់ គឺជាកត្តាសំខាន់ផ្សេងៗទៀតក្នុងរឿងនេះ ។

ការស្រាវជ្រាវពីបញ្ហាសេដ្ឋកិច្ចប្រើរូបិយវត្ថុពីររបស់កម្ពុជា វាស្ថិតនៅក្រៅដែនកំណត់នៃការសិក្សានេះ ដូច្នេះ យើងសូមលើកយកចំណុចសំខាន់ៗបី

៥ មូលធនពីបរទេស រួមចំណែកប្រហែល ៧៣% ក្នុងមូលធនបានបង់ជំរះសរុបរបស់វិស័យ MFI (NBC) ។

មកបង្ហាញតែប៉ុណ្ណោះ ។ ទីមួយ ដុល្លារូបនីយកម្មនាបច្ចុប្បន្នរបស់កម្ពុជា មិនមែនមានលក្ខណៈត្រង់ៗ ងាយស្វែងយល់ឡើយ ។ តាមការជជែកវែកញែក ដុល្លារូបនីយកម្ម ចែកចេញជា"ដំណឹងល្អ" និង"ដំណឹងអាក្រក់" គឺបានន័យថា វាឆ្លុះបញ្ចាំងទាំងជោគជ័យនៃសេដ្ឋកិច្ចកម្ពុជាក្នុងទសវត្សរ៍កន្លងទៅ និងទាំងភាពអន់ថយនៃវិស័យហិរញ្ញវត្ថុក្នុងស្រុក ស្ថាប័ន និងក្របខ័ណ្ឌច្បាប់ ក៏ដូចជា បញ្ហាខាងប្រវត្តិសាស្ត្រ (CDRI 2009c; Menon 2008) ។

ទីពីរ ហេតុផលត្រូវគាំទ្រ ឬត្រូវប្រឆាំងនឹងដុល្លារូបនីយកម្ម ក៏មិនច្បាស់លាស់ដាច់ណាត់ដែរ ។ ចំណាយសំខាន់ៗនៃដុល្លារូបនីយកម្មដែលគេបានអះអាងឡើង រួមមានការខាតបង់ចំណូលដែលទទួលបានពីការចេញផ្សាយក្រដាសប្រាក់ ការបាត់បង់លទ្ធភាពរបស់ធនាគារកណ្ដាលក្នុងការដើរតួជាអ្នកផ្ដល់កម្ចីចុងក្រោយគេ និងការបាត់បង់គោលនយោបាយរូបិយវត្ថុដែលមានលក្ខណៈឯករាជ្យ ហើយទាំងអស់នេះ វាកាត់បន្ថយលទ្ធភាពក្នុងការឆ្លើយតបនឹងការប៉ះទង្គិចពីខាងក្រៅ ។ដោយមិនបាច់និយាយដល់អត្ថប្រយោជន៍នៃដុល្លារូបនីយកម្មផង គេក៏មិនគួរវាយតម្លៃពីការខាតបង់ ដោយមិនពិចារណាពីកត្តាឯទៀតៗ ជាពិសេស កត្តាផ្សេងៗ ដែលអាចជួយសំរាលការខាតបង់ ដូចជាផលប្រយោជន៍ខាងហិរញ្ញវត្ថុនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលកើតឡើងពីឥទ្ធិពលល្អនៃដុល្លារូបនីយកម្ម (ជួយកាត់បន្ថយអតិផរណា អត្រាការប្រាក់ និងហានិភ័យខាងរូបិយវត្ថុ) ជាដើម ដែលអាចប៉ះប៉ូវនូវការខាតបង់ចំណូលទទួលបានពីការចេញផ្សាយក្រដាសប្រាក់ ។

**សកម្មភាពទាំងឡាយដែល NBC បានធ្វើកន្លងមក ពិតជាទាន់ពេល និងអាចបង្ការគ្រោះថ្នាក់បានល្អ គួរឱ្យកោតសរសើរ ។**

ទីបី ក្រៅពីធនាគារកណ្ដាល នៅមានប្រភពផ្ដល់សាច់ប្រាក់ងាយស្រួលដទៃទៀត ដែលជួយបង្ការគ្រោះថ្នាក់នៃសាធនភាព និងកង្វះសាច់ប្រាក់ងាយស្រួល ដែលជាប់ទាក់ទងនឹងដុល្លារូបនីយកម្ម ក្នុងពេលមានវិបត្តិ ។ នៅពេលស្ថាប័នរូបិយវត្ថុនានា កំពុងប្រឈមមុខនឹងបញ្ហាបាត់បង់ទំនុកចិត្តដែរនោះ សេណារីយ៉ូនៃការលុបចោលដុល្លារូបនីយកម្ម អាចចោទបញ្ហាកាន់តែស្មុគស្មាញ និងធ្វើឱ្យបាត់បង់ឱកាសទាញយកចំណេញពីតួនាទីជាឧបករណ៍បញ្ជាក់កិច្ចសន្យានៃដុល្លារូបនីយកម្ម (សូមមើល Chang & Velasco 2002; Schmitt-Grohé & Uribe 2000; Alvarez-Plata & Garcia-Herrero 2008; Antinolfi & Keister 2001; Edwards & Magendzo 2003; Baliño *et al*. 1999) ។

ឆ្លងតាមការពិចារណាដូចខាងលើ យើងឃើញថា លទ្ធភាពរបស់ NBC ក្នុងការឆ្លើយតបនឹងវិបត្តិពិតជាមានកម្រិតព្រំដែនជៀសមិនផុត ។ទោះយ៉ាងណាក្ដី សកម្មភាពទាំងឡាយដែល NBC បានធ្វើកន្លងមក ពិតជាទាន់ពេល និងអាចបង្ការគ្រោះថ្នាក់ បានល្អគួរឱ្យកោតសរសើរ ។ ពិសេសទៅទៀត ដោយសារវិបត្តិសាកលបានកើតឡើងភ្លាមៗ បន្ទាប់ពីមានកំណើនថ្លៃទំនិញខ្ពស់ជាខ្លាំងនោះ ធនាគារកណ្ដាល ត្រូវបន្សុំពេលគ្នាយ៉ាងប្រុងប្រយ័ត្នរវាងការបន្ធូរបន្ថយការរឹតបន្តឹងខាងរូបិយវត្ថុ និងការកាត់បន្ថយអតិផរណា ។នៅពេលថ្លៃទំនិញ ធ្លាក់ចុះជាបណ្ដើរៗមកវិញនោះ NBC បានកាត់បន្ថយការតំរូវធនបំរុងពី ១៦% មកត្រឹម ១២% ដើម្បីដាក់បញ្ចូលសាច់ប្រាក់ងាយស្រួលបន្ថែមមកក្នុងប្រព័ន្ធធនាគារ ។NBC បានលុបចោលនូវការដាក់កម្រិតលើការផ្ដល់ឥណទានទៅឱ្យវិស័យអចលនទ្រព្យ ដើម្បីបញ្ឈប់ការរំលំរលាយដំណើរការរីកដុះដាលលឿន ។ ធនាគារជាតិ ក៏បានបង្កើតសេវាឥណទានលើសសមតុល្យ (ទោះបីពីដំបូងមានប្រាក់សម្រាប់គាំទ្រត្រឹម ១០០លានដុល្លារ [CEW 2009]) សម្រាប់ជួយដល់ធនាគារដែលនៅមានលទ្ធភាពសងបំណុលគេ និងដែលកំពុងជួបកង្វះខាតសាច់ប្រាក់ងាយស្រួលជាបណ្ដោះអាសន្ន ។ NBC បានចេញបទបញ្ជាតឹងរ៉ឹងជាងមុនស្ដីពីការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មឡើងវិញ និងការធ្វើសវិធានធន ដើម្បីកំណត់បានកាន់តែត្រឹមត្រូវលើស្ថានភាពឥណទានមិនដំណើរការ និងធានាឱ្យធនាគារនានា មានស្ថានភាពប្រសើរជាងមុនក្នុងការទប់ទល់នឹងការខាតបង់ផ្សេងៗ ។ NBC ក៏បានរឹតបន្តឹងបទបញ្ជាស្ដីពីការរាយការណ៍ពីហានិភ័យធំៗ ដើម្បីអាចវាយតម្លៃបានប្រសើរជាងមុនពីការប្រមូលផ្ដុំហានិភ័យខាងឥណទាន ។ NBC បានពង្រឹងការត្រួតពិនិត្យដល់ទីកន្លែង និងការត្រួតពិនិត្យលើឯកសារ ទាំងជាលក្ខណៈទៀងទាត់ និងមិនទៀងទាត់ ។ NBC ក៏បានចាប់ផ្ដើមផ្ដល់អាជ្ញាប័ណ្ណអនុញ្ញាតឱ្យ MFIs អាចប្រមូលទទួលយកប្រាក់បញ្ញើពីសាធារណជនដោយផ្ទាល់ដែរ (Keat 2009; CEW 2009; Jalilian *et al*. 2009; Chhun 2009; see also NBC—www.nbc.org.kh/index.asp) ។

គេគួរអនុវត្តជំហានមួយចំនួនថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាព និងជៀសវាងបញ្ហាផ្សេងៗទៅថ្ងៃមុខ ។ ចន្លោះប្រហោងដែលអាចកើតមានក្នុងការត្រួតពិនិត្យលើឥណទានមិនដំណើរការ ត្រូវបិទឱ្យជិត ព្រោះការវិនិច្ឆ័យក្នុងផ្លូវខុសបង្កឡើងនូវអារម្មណ៍សុខសាន្តខុសទំនង ដែលនាំឱ្យមានការធ្វេសប្រហែស ឬការឆ្លើយតបខុសផ្លូវ ។ សំខាន់ជាងការឆ្លើយតបឆាប់រហ័សទៅនឹងតំរូវការរយៈពេលខ្លីនៃវិបត្តិទៅទៀត គេត្រូវអនុវត្តជំហានធំៗកែលំអប្រព័ន្ធហិរញ្ញវត្ថុឱ្យបានស៊ីជំរៅ ដើម្បីពង្រឹងសមត្ថភាពសម្រាប់ទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅ និងជៀសវាងករណីដែលប្រព័ន្ធហិរញ្ញវត្ថុខ្លួនឯងក្លាយជាប្រភពនៃវិបត្តិ ។ នាបច្ចុប្បន្ន រចនាសម្ព័ន្ធហិរញ្ញវត្ថុនៅក្មេងខ្ចីនៅឡើយ ឧបករណ៍ហិរញ្ញវត្ថុក៏មានតិច ទីផ្សារអន្តរធនាគារក៏នៅអន់ថយ ទីភ្នាក់ងារផ្ដល់ចំណាត់ថ្នាក់ និងធានារ៉ាប់រងប្រាក់បញ្ញើជាផ្លូវការ ក៏មិនទាន់មាន ហើយការចែកចាយព័ត៌មានឥណទានក៏មានតិចដែរ (Pak *et al*. 2008)។ NBC កំពុងពិចារណាយ៉ាងប្រុងប្រយ័ត្នលើជំរើសនានាសម្រាប់ដោះស្រាយចំណុចខ្វះខាតទាំងនេះ និងគិតគូរថ្លឹងថ្លែងពីផលប្រយោជន៍ និងគុណវិបត្តិនៃមធ្យោបាយសម្រាប់ដោះស្រាយនានា និងសមត្ថភាពនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងការអនុវត្តមធ្យោបាយទាំងនេះ ។ ចំពោះការងារផ្ទៃក្នុងវិញ NBC កំពុងព្យាយាមកសាងសមត្ថភាពបុគ្គលិករបស់ខ្លួន ដោយប្រើប្រាស់ធនធានដែលខ្លួនមាន (ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ) ។

ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ក៏នៅខ្វះទីផ្សារហ៊ុនដែលមានសារៈសំខាន់ច្រើនដែរ ។ កង្វះនេះ បានជួយការពារប្រទេសកម្ពុជាឱ្យរួចផុតពីឥទ្ធិពលដោយផ្ទាល់ចំបង១ និងឥទ្ធិពលឆ្លងរាលដាលនៃវិបត្តិហិរញ្ញវត្ថុក៏ពិតមែន ប៉ុន្តែវាក៏ជាឧបសគ្គផងដែរ ដល់ការបង្កើតមូលនិធិបន្ថែមសម្រាប់ជួយជំរុញស្ថានភាពសេដ្ឋកិច្ចយ៉ាប់យ៉ឺន ក៏ដូចជា តារាងតុល្យការមានខ្ទង់ខូចខាតច្រើនរបស់ធនាគារ ។ បញ្ហាខាងលើ ស្ថិតនៅខាងក្រៅដែនកំណត់នៃអត្ថបទនេះ ដូច្នេះ យើងគ្រាន់តែបញ្ជាក់យ៉ាងខ្លីថា ថ្វីបើរដ្ឋាភិបាលមានឯកសារផែនការវិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ដែលមានកំណត់ពីវិធានការត្រៀមមួយចំនួន (រួមទាំងការដាក់អនុវត្តច្បាប់ និងបទបញ្ញត្តិដ៏ចាំបាច់ និងការបង្កើតគណៈកម្មការមូលបត្រផង) ក៏នៅខ្វះបុព្វលក្ខខណ្ឌជាច្រើនសម្រាប់ឱ្យទីផ្សារហ៊ុនដំណើរការបានដោយជោគជ័យ ។ គោលដៅចំបងនៃការអភិវឌ្ឍទីផ្សារមូលធន គឺដើម្បីធ្វើការប្រមែប្រមូលប្រាក់សន្សំ ប៉ុន្តែអត្រាប្រាក់សន្សំក្នុងស្រុក មានកម្រិតទាប ដែលបណ្ដាលមួយចំណែកមកពី កម្រិតយល់ដឹងទាបខាងហិរញ្ញវត្ថុរបស់សាធារណជន និងកង្វះទំនុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុ ។ បញ្ហាដទៃទៀតរួមមាន មូលដ្ឋានវិនិយោគិនតូចចង្អៀត ការអនុវត្តមិនបានល្អតាមស្ដង់ដារតម្លាភាព និងអភិបាលកិច្ចរបស់ក្រុមហ៊ុន ដែលប៉ះពាល់ដល់ទំហំនៃអ្នកចេញផ្សាយសន្លឹកហ៊ុនមានសិទ្ធិ និង អវត្តមាននៃអន្តរការីសន្លឹកហ៊ុន ។

## ចក្ខុវិស័យ និងហានិភ័យ

ទោះបីជាសេដ្ឋកិច្ចកម្ពុជា និងសេដ្ឋកិច្ចសាកល បានចាប់ងើបឡើងវិញ ហើយលទ្ធផលក៏សំរេចបានគួរឱ្យពេញចិត្ត យោងតាមសូចនាករភាពរឹងមាំខាងហិរញ្ញវត្ថុក៏ដោយ ក៏នៅតែមានការព្រួយបារម្ភពីភាពរឹងមាំនៃវិស័យធនាគារដដែល ។ ប៉ុន្តែការព្រួយបារម្ភនេះ ប្រែប្រួលខុសៗគ្នា គឺអ្នកដែលមិនសូវទុទិដ្ឋិនិយម បានសំលឹងឃើញការងើបឡើងវិញនៃវិស័យអចលនទ្រព្យ ហើយច្រើនផ្ដោតការគិតគូរលើស្ថានភាព ដូចជា ការប្រែប្រួលមិនល្អជាយថាហេតុនៃឥណទានមិនដំណើរការ ដែលជះឥទ្ធិពលតែលើធនាគារខ្លះប៉ុណ្ណោះ ។ រីឯអ្នកទុទិដ្ឋិនិយមខ្លាំងវិញ គេផ្ដោតការយកចិត្តទុកដាក់លើបញ្ហាបង្កប់ផ្សេងៗ លើធនាគារកណ្ដាល ដែលត្រូវរ៉ាប់រងការងារស្មើរហួសសមត្ថភាព និងហានិភ័យពីខាងក្រៅ ដូចជា ការធ្លាក់ចុះពីរដងនៃសេដ្ឋកិច្ចសាកល នៅពេលគេដកចេញវិញនូវកម្មវិធីជំរុញវិស័យហិរញ្ញវត្ថុនានា ។ សរុបមក អ្នកមិនសូវទុទិដ្ឋិនិយម គិតថា គ្រោះថ្នាក់បានកន្លងផុតហើយ ប៉ុន្តែអ្នកទុទិដ្ឋិនិយមខ្លាំង បានក្រើនរំលឹកថា នៅពេលខាងមុខ អាចមានស្ថានភាពអាក្រក់ជាងនេះទៀត ។

## ប្រភព:

ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅចន្លោះខែតុលា និងវិច្ឆិកា ២០០៩

ADB (2009), *Asia Economic Outlook Update* (Manila: ADB)

Alvarez-Plata, P. & A. Garcia-Herrero (2008), *To Dollarize or De-dollarize: Consequences for Monetary Policy*, DIW Discussion Paper 842 (Berlin: DIW)

Antinolfi, G. & T. Keisner (2001), "Dollarization as a Monetary Arrangement for Emerging Market Economies", *Review*, November (Federal Reserve Bank of St Louis)

Baliño, T., A. Bennett & E. Borenzstein (1999), *Monetary Policy in Dollarized Economies (Overview)*, IMF Occasional Paper 171 (Washington, DC: IMF)

Cambodia Economic Watch (CEW) (2009), *Economics Today*, Special Issue, July (Vol. 2, No. 42)

CDRI (2009a), *Cambodia Outlook Briefs* (Phnom Penh: CDRI)

CDRI (2009b), *Cambodia Development Review*, April –June (Phnom Penh: CDRI)

CDRI (2009c), "Cambodia Country Report", prepared for the International Conference on East Asian Economy in Beijing, 22–23 October

Chang, R. & A. Velasco (2002), *Dollarization: Analytical Issues*, NBER Working Paper 8838 (Cambridge: NBER)

Chhun, S. (2009), "Can MFIs Survive?", *Economics Today*, Vol. 2, No. 37

Edwards, S. & I.I. Magendzo (2003). *Strict Dollarization and Economic Performance: An Empirical Investigation*, NBER Working Paper 9820 (Cambridge: NBER)

Keat Chhon (2009), "Keynote Address on the Occasion of the Official Inauguration of the Securities and Exchange Commission", 29 April

IMF (2009a), *Country Report No. 09/47*, Cambodia: 2008 Article IV Consultation—Staff Report; Staff Supplement; and Public Information Notice on the Executive Board Discussion (Washington, DC: IMF)

IMF (2009b), "Statement at the Conclusion of an IMF Staff Mission to Cambodia", Press Release No. 09/325

IMF (2009c), *World Economic Outlook: Sustaining the Recovery* (Washington, DC: IMF)

Jalilian, H., S. Chan, G. Reyes, C.H. Saing, D. Pon, & D. Phann (2009), *Cambodia*, Global Financial Crisis Discussion Paper Series, 3 (London: ODI)

Menon, Jayant (2008), *Cambodia's Persistent Dollarization: Causes and Policy Options*, ADB Working Paper Series on Regional Economic Integration, No. 19 (Manila: ADB)

Nguon, S. (2009). Bad Loans Rising, *Phnom Penh Post*, 27 August.

Pak, S., T. Hourn & M. Biallas (2008), *Cambodia Financial Sector Diagnostic* (Washington, DC: IFC)

Prakas on Asset Classification and Provisioning in Banking and Financial Institutions, http://www.nbc.org/read-prakas/asp?id=63.

Schmitt-Grohé, S. & M. Uribe (2000), *Stabilization and the Costs of Dollarization*, Departmental Working Papers 200006 (New Brunswick: Rutgers University)

World Bank (2009a), *East Asia and Pacific Update —Battling the Forces of Global Recession* (Washington, DC: World Bank)

World Bank (2009b), *East Asia and Pacific Update —Transforming the Rebound into Recovery* (Washington, DC: World Bank)